# ព្រះរាជក្រឹត្យ

នស/រកត/១២១៤/១៤៩៧

## ស្តីពី

## ការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ជស/រកត/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា ១:**

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់ឱ្យមានក្របខណ្ឌគតិយុត្តរួមសម្រាប់គ្រប់គ្រងទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើគ្រប់ប្រភេទ។

**មាត្រា ២:**

ព្រះរាជក្រឹត្យនេះ មានគោលដៅរៀបចំការគ្រប់គ្រង ការកំណត់ប្រាក់បំណាច់ និងការបើកផ្តល់ប្រាក់បំណាច់ដល់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើគ្រប់ប្រភេទ។

**មាត្រា ៣:**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះវរជន ឬជនដែលមានសញ្ញាបត្រខ្ពស់ ឬជនដែលមានប្រយោជន៍ដល់ការងាររដ្ឋ និងមន្ត្រីរាជការស៊ីវិលដែលរួមមានមន្ត្រីរាជការក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត ព្រមទាំងនគរបាលជាតិ និងយោធិនដែលត្រូវបានតែងតាំងជាទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ។

ព្រះរាជក្រឹត្យនេះ មិនមានវិសាលភាពអនុវត្តចំពោះទីប្រឹក្សា ជំនួយការ ឬមន្ត្រីបច្ចេកទេសជាតិនិងអន្តរជាតិ ដែលត្រូវបានជ្រើសរើសដើម្បីបំពេញការងារសម្រាប់គម្រោង ឬកម្មវិធីក្រោមហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឬគម្រោង ឬកម្មវិធីជាតិដែលមានកិច្ចសន្យាការងារតាមរយៈកិច្ចលទ្ធកម្មសាធារណៈ ឬដើម្បីបំពេញការងារអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងមិនអនុវត្តចំពោះការតែងតាំងដែលផ្តល់ឋានៈស្មើចំពោះមុខតំណែងទាំងឡាយដែលមាននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនិងរដ្ឋបាលនៃក្រសួង ស្ថាប័នឡើយ។

## ជំពូកទី២
## ការគ្រប់គ្រងទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ

**មាត្រា ៤:**

ការប្រើប្រាស់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ សម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ និងស្ថាប័នសាធារណៈដទៃទៀត ឬនៅអមក្រសួង ស្ថាប័ន ដោយផ្តល់នូវប្រាក់បំណាច់តាមការកំណត់ក្នុងព្រះរាជក្រឹត្យនេះ ត្រូវអនុលោមចំនួនមុខតំណែង និងកម្រិតឥណទានដែលត្រូវបានផ្តល់ឱ្យក្រសួង ស្ថាប័ន ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ។

ការជ្រើសរើសនិងតែងតាំងទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ មិនអាចអនុវត្តបាននិងផ្តល់នូវប្រាក់បំណាច់ជូនឡើយ ក្នុងករណីដែលមិនមានឥណទានគ្រោងក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើឡើយ។

ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ មិនត្រូវបានអនុញ្ញាតឱ្យមានទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើសម្រាប់ខ្លួនឡើយ។

**មាត្រា ៥:**

ការតែងតាំងមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងយោធិន ឱ្យបំពេញមុខងារបន្ថែមជាទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ មិនត្រូវឱ្យប៉ះពាល់ដល់ការអនុវត្តកាតព្វកិច្ចជាមន្ត្រីរាជការឡើយ។

**មាត្រា ៦:**

ការតែងតាំងជាទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ នៅអមថ្នាក់ដឹកនាំកម្រិតនយោបាយរបស់ក្រសួង ស្ថាប័ន ដែលមានអាណត្តិអាស្រ័យតាមការបោះឆ្នោត ត្រូវអស់សុពលភាពជាស្វ័យប្រវត្តិនៅពេលដែលមុខតំណែងរបស់ថ្នាក់ដឹកនាំត្រូវបានបញ្ចប់។

ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ នៅអមក្រសួង ស្ថាប័ន ដែលត្រូវបានស្នើតែងតាំងដោយថ្នាក់ដឹកនាំក្រសួង ស្ថាប័នកម្រិតនយោបាយ ដែលមានអាណត្តិអាស្រ័យតាមការបោះឆ្នោត ក៏ត្រូវអស់សុពលភាពជាស្វ័យប្រវត្តិនៅពេលដែលមុខតំណែងរបស់ថ្នាក់ដឹកនាំត្រូវបានបញ្ចប់។

**មាត្រា ៧:**

ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើនឹងមុខតំណែងចាប់ពីអនុរដ្ឋលេខាធិការដល់នាយករដ្ឋមន្ត្រី មិនទទួលបាននូវបុព្វសិទ្ធិនិងសិទ្ធិអំណាចឋានានុក្រមក្នុងរាជរដ្ឋាភិបាលឡើយ។

ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើនឹងមុខតំណែងចាប់ពីអនុប្រធានការិយាល័យដល់អគ្គនាយក មិនទទួលបាននូវបុព្វសិទ្ធិនិងសិទ្ធិអំណាចឋានានុក្រមក្នុងមុខងារសាធារណៈឡើយ។

**មាត្រា ៨:**

ឋានៈស្មើនឹងមុខតំណែងក្នុងកម្រិតណាមួយរបស់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការតែងតាំងក្នុងមុខតំណែងមន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងយោធិន ព្រមទាំងសម្រាប់ការផ្លាស់ប្តូរ ការបញ្ចូលទៅក្នុងក្របខណ្ឌ និងការដំឡើងឋានន្តរស័ក្តិនិងថ្នាក់នោះឡើយ។

## ជំពូកទី៣

## ការកំណត់ប្រាក់បំណាច់សម្រាប់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ

**មាត្រា ៩:**

ប្រាក់បំណាច់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានកំណត់ដាច់ដោយឡែកនិងមិនផ្សារភ្ជាប់ជាមួយនឹងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងយោធិន ព្រមទាំងប្រាក់បំណាច់មុខងារអនុរដ្ឋលេខាធិការនិងសមាជិករាជរដ្ឋាភិបាលឡើយ។

**មាត្រា ១០**:

ប្រាក់បំណាច់ប្រចាំខែសម្រាប់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ត្រូវបានកំណត់ក្នុងតារាងដូចខាងក្រោម៖

| ល.រ | មុខតំណែងទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ | កម្រិតប្រាក់បំណាច់ (រៀល) |
|---|---|---|
| ១ | នាយករដ្ឋមន្ត្រី | ៣ ៦៧៥ ០០០ |
| ២ | ឧបនាយករដ្ឋមន្ត្រី | ២ ៨០០ ០០០ |
| ៣ | ទេសរដ្ឋមន្ត្រី | ២ ៤៥០ ០០០ |
| ៤ | រដ្ឋមន្ត្រី | ២ ១០០ ០០០ |
| ៥ | រដ្ឋលេខាធិការ | ១ ៧៥០ ០០០ |
| ៦ | អនុរដ្ឋលេខាធិការ | ១ ៤០០ ០០០ |
| ៧ | អគ្គនាយក | ៧៣៥ ០០០ |
| ៨ | អគ្គនាយករង | ៦៤៥ ០០០ |
| ៩ | ប្រធាននាយកដ្ឋាន | ៦២០ ០០០ |
| ១០ | អនុប្រធាននាយកដ្ឋាន | ៥៤០ ០០០ |
| ១១ | ប្រធានការិយាល័យ | ៧៨ ១០០ |
| ១២ | អនុប្រធានការិយាល័យ | ៦១ ៤០០ |

ការតែងតាំងទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ក្រៅពីមុខតំណែងដែលមានកំណត់ក្នុងតារាងខាងលើ មិនត្រូវបានអនុញ្ញាតឡើយ។

**មាត្រា ១១**:

បុគ្គលមិនស្ថិតក្នុងក្របខ័ណ្ឌជាមន្ត្រីរាជការ ហើយត្រូវបានតែងតាំងជាទីប្រឹក្សា ជំនួយការ លេខាធិការ ឬមន្ត្រីដែលមានឋានៈស្មើក្នុងកម្រិតណាមួយ អាចត្រូវផ្តល់ប្រាក់បំណាច់តាមការកំណត់ខាងលើ ឬមិនទទួលប្រាក់បំណាច់តាមការស្ម័គ្រចិត្ត។

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាទីប្រឹក្សា ជំនួយការ លេខាធិការ ឬមន្ត្រីដែលមានឋានៈស្មើក្នុងកម្រិតណាមួយ អាចជ្រើសរើសយកប្រាក់បំណាច់តាមការកំណត់ខាងលើ ឬរក្សាប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការ។

បុគ្គលមិនស្ថិតក្នុងក្របខ័ណ្ឌជាមន្ត្រីរាជការ និងមន្ត្រីរាជការ ដែលត្រូវបានតែងតាំងជាទីប្រឹក្សា ជំនួយការ លេខាធិការ ឬមន្ត្រីដែលមានឋានៈស្មើក្នុងកម្រិតណាមួយ មិនអាចទទួលបានប្រាក់បំណាច់លើសពីមួយបានឡើយ ទោះបីក្នុងក្រសួង ស្ថាប័នតែមួយ ឬក្រសួង ស្ថាប័នផ្សេងគ្នាក៏ដោយ។

**មាត្រា ១២**:

ការបើកផ្តល់ប្រាក់បំណាច់សម្រាប់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ដែលមិនមែនជាមន្ត្រីរាជការ ត្រូវអនុវត្តនៅក្រសួង ស្ថាប័ន ដែលសាមីជនទទួលការតែងតាំង។

ការបើកផ្តល់ប្រាក់បំណាច់សម្រាប់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ដែលជាមន្ត្រីរាជការ ត្រូវអនុវត្តនៅក្រសួង ស្ថាប័ន ដែលសាមីជនមានក្របខណ្ឌ។

**មាត្រា ១៣**:

ការកែប្រែប្រាក់បំណាច់ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១៤**:

ការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ មានប្រសិទ្ធភាពអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៥ តទៅ។

## ជំពូកទី៤
## អវសានបញ្ញត្តិ

**មាត្រា ១៥**:

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧. ១៤១២. ១៥១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ១៥៧៣ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**